**មាត្រា ១៦** : អាជ្ញាធរ « អប្សារា » មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និងត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

## អនុក្រឹត្យ លេខ ០២ អនក្រ.បក

## ស្តីពីការកែសំរួលទំហំដី តំបន់ឧស្សាហកម្មស្ទឹងហាវ

## ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតតំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល និង តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១ :** មាត្រា ៤ នៃអនុក្រឹត្យលេខ ៧៣ អនក្រ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត តំបន់ឧស្សាហកម្មស្ទ...ារ ក្រុងព្រះសីហនុ ត្រូវបានកែសំរួលដូចតទៅ ÷

១-តំបន់ឧស្សាហកម្ម ស្ទឹងហាវ ក្រុងព្រះសីហនុ មានទំហំប្រមាណ ១.១០០ ហិកតា មានទីតាំងដូច បានបញ្ជាក់តាមផែនទីដែលមានភ្ជាប់នឹងអនុក្រឹត្យនេះ និង ដែលស្ថិតនៅក្នុងចន្លោះ :

**ចាប់ពី**

ខ្សែរយៈទទឹង ១០° ៤៣,២ ខ្សែរយៈបណ្តោយ ១០៣° ៣២,៨

និងខ្សែរយៈទទឹង ១០° ៤២,៣ ខ្សែរយៈបណ្តោយ ១០៣° ៣២,៩

**ទៅដល់**

ខ្សែរយៈទទឹង ១០° ៤៤,១ ខ្សែរយៈបណ្តោយ ១០៣° ៣៧,២

និងខ្សែរយៈទទឹង ១០° ៤៣,២ ខ្សែរយៈបណ្តោយ ១០៣° ៣៧,៤

អាងទឹកសាបដែលមានសញ្ញាបញ្ជាក់ក្នុងផែនទីដែលភ្ជាប់នឹងអនុក្រឹត្យនេះ ជាប្រភពទឹក សាបសំរាប់បំរើសេចក្តីត្រូវការរបស់តំបន់ឧស្សាហកម្ម ស្ទឹងហាវ ក្រុងព្រះសីហនុ ។

២-តំបន់រោងចក្រចំរាញ់ប្រេងកាត ឃ្លាំងស្តុកប្រេងឥន្ធនៈ និង បុរីកម្មករ នៅស្ទឹងហាវ ក្រុងព្រះ សីហនុ មានទំហំប្រមាណ ៥០ ហិកតា មានទីតាំងនៅជាប់តំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះ សីហនុ ដូចបានបញ្ជាក់ក្នុងផែនទី ដែលមានភ្ជាប់នឹងអនុក្រឹត្យនេះ ជាកម្មសិទ្ធិរបស់រដ្ឋ ហើយត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

# ផែនទី

## តំបន់ឧស្សាហកម្ម ស្ទឹងហាវ - ខេត្តព្រះសីហនុ

តំបន់ឧស្សាហកម្មទូទៅ ≈១១០០ ហិកតា




កំណត់សំគាល់

- អាងទឹកសាប
- ខណ្ឌសីមានៃតំបន់ឧស្សាហកម្មទូទៅ
- ផ្លូវរថភ្លើង
- រោងចក្រចំរាញ់ប្រេងកាត

0 500 1000 1500 ម៉ែ

ព័ន្ធ និង អភិបាលក្រុង ព្រះសីហនុ មានភារកិច្ចអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះតាមសមត្ថកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្ថលេខា និងត្រា** | **ហត្ថលេខានិងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៦

**អនុក្រឹត្យ លេខ ០១ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

**សំរេច**

**មាត្រា ១ :** ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះសប្បុរសជនដែលបានបរិច្ចាគថវិកា ជួយកសាងនិងជួសជុលអាគារសិក្សា ព្រមទាំងបំពាក់សំភារៈបរិក្ខារ